## មេរៀនទី ១ :

# រចនាសម្ព័ន្ធគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅកម្ពុជា

## I- ប្រវត្តិសង្ខេប :

នៅឆ្នាំ ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ( National Committee for Disaster Management ) ហៅកាត់ថា ( គ.ជ.គ.ម ) ( NCDM )។ ជាបន្តបន្ទាប់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានរៀបចំ និងកែលំអ ហើយនៅឆ្នាំ២០០៤ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានរាជរដ្ឋាភិបាល ទូលថ្វាយព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា សុំត្រាស់បង្គាប់បង្កើត គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ តាមព្រះរាជក្រឹត្យលេខ នស.រកត.០២០២.០៤០ ចុះថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០០២ និងព្រះរាជក្រឹត្យលេខ នស.រកត.០៨០៤.២៣៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤។

## II- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ :

### ក- សមាសភាពគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ :

| | |
|---|---|
| ១. នាយករដ្ឋមន្ត្រី | ប្រធាន |
| ២. ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី១ |
| ៣. ឥស្សរជនជាន់ខ្ពស់មួយរូប | អនុប្រធានទី២ |
| ៤. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥. រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៦. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. រដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩. រដ្ឋមន្ត្រី ក្រសួងបរិស្ថាន | សមាជិក |
| ១០. រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| ១១. រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | សមាជិក |
| ១២. រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. រដ្ឋមន្ត្រី ក្រសួងសុខាភិបាល | សមាជិក |
| ១៤. រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥. រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១៦. រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |

| | |
|---|---|
| ១៧. រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១៨. រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៩. រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | សមាជិក |
| ២០. តំណាងអគ្គមេបញ្ជាការកងយោធិពលខេមរភូមិន្ទ | សមាជិក |
| ២១. តំណាងប្រធានកាកបាទក្រហមជាតិកម្ពុជា | សមាជិក |
| ២២. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |

**ខ- បេសកកម្ម :** ដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយ នៅព្រះរាជាណាចក្រកម្ពុជា ។

**គ- មុខងារ និងភារកិច្ច :**

១- អង្កេតតាមដានវាយតំលៃប្រមូលវិភាគ គ្រប់គ្រងទិន្នន័យគ្រោះភ័យនៃគ្រោះមហន្តរាយនិងរៀបចំចងក្រងរបាយការណ៍ ស្តីពីស្ថានភាពគ្រោះមហន្តរាយ ដើម្បីផ្តល់យោបល់ជូនរាជរដ្ឋាភិបាលដាក់ចេញនូវគោលការណ៍ គោលនយោបាយ , សារាចរ , សេចក្តីប្រកាស និងវិធានការណ៍ សំរាប់ការ គ្រប់គ្រងគ្រោះមហន្តរាយ ។

២- លើកសំណើជូនរាជរដ្ឋាភិបាលអំពីសេចក្តីត្រូវការ និងការប្រើប្រាស់ប្រភពធនធាន ដូចជា មូលនិធិ សម្ភារៈប្រេងឥន្ធនៈ មធ្យោបាយប្រើប្រាស់ និងធនធានមនុស្ស ដើម្បីដំណើរការកិច្ចប្រតិបត្តិការ ការងារគ្រប់គ្រងគ្រោះមហន្តរាយ និងសំរាប់ជួយដល់ជនរងគ្រោះ ដែលប៉ះពាល់ពីមុខសញ្ញាគ្រោះថ្នាក់ ដោយធម្មជាតិ និងដោយមនុស្ស ។

៣- អភិវឌ្ឍធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបច្ចេកទេស ជំនាញ និងចំណេះដឹងដល់មន្ត្រីទទួលបន្ទុកការងារគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ជាតិ ក្រសួងពាក់ព័ន្ធ រាជធានី-ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់-ភូមិ និងអប់រំផ្សព្វផ្សាយការយល់ដឹងសាធារណៈដល់ប្រជាពលរដ្ឋនៅសហគមន៍ អំពីគ្រោះភ័យនៃគ្រោះមហន្តរាយដោយធម្មជាតិ និងដោយមនុស្ស ។

៤- សហការជាមួយក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ព្រមទាំងសប្បុរសជនផង ដើម្បីអនុវត្តដែលជាគោលនយោបាយជាតិនៃការងារគ្រប់គ្រងគ្រោះមហន្តរាយ ដូចជាការត្រៀមបង្ការ ការសំរាល ការត្រៀមរៀបចំដើម្បីទប់ទល់ទៅនឹងមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិនិងដោយមនុស្ស ។

៥- ធ្វើការទំនាក់ទំនងសំរបសំរួលកិច្ចសហប្រតិបត្តិការថ្នាក់ជាតិ ថ្នាក់តំបន់ និងកិច្ចសហប្រតិបត្តិការ អន្តរជាតិ ក្នុងការផ្តល់ពត៌មានឱ្យគ្នាទៅវិញទៅមកអំពីស្ថានភាព និងស្ថានការណ៍គ្រោះមហន្តរាយ សំដៅកាត់បន្ថយផលប៉ះពាល់ពីគ្រោះមហន្តរាយ ។

៦- ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុងស្រុក ដើម្បីកៀរគរស្វែងរកជំនួយ សំរាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញរាល់ការខូចខាត ដោយគ្រោះមហន្តរាយ ។

**ឃ- រចនាសម្ពន្ធ័របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មាន រចនាសម្ព័ន្ធ ដូចតទៅ :

១- ខុទ្ទកាល័យ ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

២- អគ្គលេខាធិការដ្ឋាន រួមមាន នាយកដ្ឋាន ៥ :

- នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ
- នាយកដ្ឋាន ពតិមាន និង ទំនាក់ទំនង
- នាយកដ្ឋាន ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ
- នាយកដ្ឋាន ត្រៀមរៀបចំ និងបណ្តុះបណ្តាល
- នាយកដ្ឋានសំរបសំរួល ការងាររុករក ឧបទ្ទវហេតុ យន្តហោះ និងនាវា

៣- ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយក្រសួងស្ថាប័ន

៤- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត-ក្រុង មានលេខាធិការដ្ឋានមួយ ជាជំនួយការ

៥- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក-ខ័ណ្ឌ មានលេខាធិការដ្ឋានមួយ ជាជំនួយការ

៦- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់ មានលេខាធិការដ្ឋានមួយ ជាជំនួយការ

**ង- ខុទ្ទកាល័យប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

ខុទ្ទកាល័យប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ទទួលបន្ទុកសំរួលរាល់កិច្ចការប្រធាន ជាក់ស្តែង អនុប្រធានទី១ ជំនួសមុខឱ្យប្រធាន ដោះស្រាយគ្រប់កិច្ចការ និងប្រតិបត្តិការផ្ទាល់ ដោយសរុបរបាយការណ៍ជូនប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះ មហន្តរាយ រីឯអ្នកជំនួយការក៏ត្រូវបំរើអោយការងារអនុប្រធានទី១។

ភារកិច្ចរបស់ខុទ្ទកាល័យមានជាអាទិ៍ :

- វ៉ាប់រង ទំនាក់ទំនងការងារ
- ផ្តល់យោបល់ជូនប្រធាន ឬអនុប្រធានទី១ គ.ជ.គ.ម ចំពោះកិច្ចការទូទៅ និងចំពោះសំណុំរឿងទាំងឡាយដែលប្រធាន ឬអនុប្រធានទី១ បានប្រគល់អោយពិនិត្យ ។

- ចែកផ្សាយអំពីគោលការណ៍ណែនាំ របស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម។
- រៀបចំ កាលវិភាគរបស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- រៀបចំសម័យប្រជុំការងារ គ.ជ.គ.ម។
- បញ្ជូនបញ្ហាប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។
- តាមដានការអនុវត្តន៍បទបញ្ជារបស់ប្រធាន ឬ អនុប្រធានទី១ គ.ជ.គ.ម ។

**ច- អគ្គលេខាធិការដ្ឋាន**

អគ្គលេខាធិការដ្ឋានមានភារកិច្ចជាសេនាធិការ ឱ្យគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានអគ្គលេខាធិការ១រូប និងអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់ និងមាននាយកដ្ឋានចំនួន ៥ ដូចខាងក្រោម :

១. នាយកដ្ឋាន រដ្ឋបាល និងហិរញ្ញវត្ថុ

២. នាយកដ្ឋាន ពត៌មាន និងទំនាក់ទំនង

៣. នាយកដ្ឋាន ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើងវិញ

៤. នាយកដ្ឋាន ត្រៀមរៀបចំ និងបណ្តុះបណ្តាល

៥. នាយកដ្ឋាន សំរបសំរួលការងាររុករក ឧបទ្ទវហេតុយន្តហោះ និង នាវា។

អគ្គលេខាធិការដ្ឋានមានភារកិច្ច និងការទទួលខុសត្រូវដូចតទៅ :

- ធានានិរន្តរភាពនៃដំណើរការរដ្ឋបាលរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។
- សិក្សាស្រាវជ្រាវតំបន់ងាយរងគ្រោះដោយទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ ជំងឺរាតត្បាត និងមុខសញ្ញាគ្រោះថ្នាក់ដទៃទៀត ដោយរៀបចំផែនការ ត្រៀមបង្ការ ឆ្លើយតបសង្គ្រោះបន្ទាន់។
- ណែនាំការងារ ជំនាញបច្ចេកទេសដល់លេខាធិការដ្ឋាន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ សហគមន៍ជួយសង្គ្រោះដើម្បីជាមូលដ្ឋាន ក្នុងការប្រមូល ទិន្នន័យគ្រោះមហន្តរាយសំរាប់ធ្វើការវាយតំលៃប៉ាន់ស្មានអំពីការខូចខាត និងតំរូវការ និងរៀបចំកម្មវិធី ស្តារ និងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដោយសំរបសំរួលការងារជាមួយស្ថាប័ន នានា ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធ។
- លើកផែនការបណ្តុះបណ្តាលជំនាញបច្ចេកទេស ដល់បុគ្គលិកគ្រប់គ្រងគ្រោះមហន្តរាយ ថ្នាក់កណ្តាល រាជធានី-ខេត្ត-ក្រុង, ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់ និងសហគមន៍ជួយសង្គ្រោះ ក្នុងក្របខ័ណ្ឌ បណ្តុះបណ្តាល ក្នុងប្រទេស និងក្រៅប្រទេស ។
- សំរបសំរួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ អាជ្ញាធរដែនដី ទីភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ដើម្បីជំលៀសប្រជាជនងាយរងគ្រោះទៅទីសុវត្ថិភាព ការពារសន្តិសុខ អប់រំសាធារណៈ ឆ្លើយតបសង្គ្រោះបន្ទាន់ និងរៀបចំកម្មវិធីផ្សេង ៗ ។

- លើកយោបល់រាល់លិខិតស្នាមពាក់ព័ន្ធ ការងារគ្រប់គ្រងគ្រោះមហន្តរាយ និងលិខិតព្រមព្រៀង បូកសរុបរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

**ឆ- ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួង ស្ថាប័ន**

ក្រុមការងារគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងស្ថាប័ន ត្រូវបានបង្កើតឡើងដោយ ក្រសួង ស្ថាប័ននីមួយៗផ្ទាល់ ដើម្បីបង្កើនការលើកកំពស់ស្មារតី ភាពម្ចាស់ការចូលរួមដោះស្រាយ គ្រោះមហន្តរាយ និងមានភារកិច្ចទទួលខុសត្រូវ ដើម្បីធ្វើការសំរបសំរួល រាល់សកម្មភាព ក្នុងការត្រៀមរៀបចំ ឆ្លើយតបគ្រោះមហន្តរាយ និងស្តារឡើងវិញ។

**ជ- យុទ្ធសាស្ត្រគ្រប់គ្រង និងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ**

ឆ្លើយតបនឹងសភាពការណ៍គ្រោះមហន្តរាយនៅតែបន្តផលប៉ះពាល់ដល់កម្ពុជានៅរៀងរាល់ឆ្នាំ បង្កការរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ និងធ្វើឱ្យសហគមន៍ងាយរងគ្រោះជាប់ក្នុងរង្វង់នៃភាពក្រីក្រ រួមជាមួយបំលាស់ប្តូរអាកាសធាតុដ៏អាក្រក់ ដែលបង្កឱ្យកើតមាននូវគ្រោះធម្មជាតិ ព្រមទាំងការគំរាមកំហែងនៃជម្ងឺផ្តាសាយបក្សី និងផ្តាសាយមនុស្សរាតត្បាតជាសាកល គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវប្រឈមជាមួយតួនាទីរបស់ខ្លួនដែលកាន់តែមានច្រើនឡើង។ ដូច្នេះគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ មានតួនាទីជាយន្តការនាំមុខដើម្បីគាំទ្រដល់សហគមន៍ឱ្យមានសមត្ថភាពទប់ទល់បាននឹងគ្រោះមហន្តរាយដោយធម្មជាតិ ស្របតាមផែនការសកម្មភាពក្រុង **HYOGO** ក្នុងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និងបំពេញបេសកកម្មជាយុទ្ធសាស្ត្រ ដោយសម្របសម្រួលជាមួយអន្តរក្រសួង ឆ្ពោះទៅការកសាងប្រព័ន្ធប្រសិទ្ធភាពមួយនៃការគ្រប់គ្រងគ្រោះមហន្តរាយ រួមទាំងការត្រៀមបង្ការ ការកាត់បន្ថយគ្រោះថ្នាក់ ការត្រៀមរៀបចំ ការឆ្លើយតប និងការស្តារឡើងវិញ ។

ជ.១- ទិសដៅយុទ្ធសាស្ត្រ

១- ពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ

២- អភិវឌ្ឍន៍ធនធានមនុស្ស និងសមត្ថភាពស្ថាប័ន

៣- ពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ

៤- ពង្រឹងសមត្ថភាពត្រៀមរៀបចំ និងឆ្លើយតបគ្រោះមហន្តរាយ

៥- រួមបញ្ចូលគោលគំនិតកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលនៅគ្រប់ផ្នែកគ្រប់ថ្នាក់ ។

## III- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត

**ក- សមាសភាព :**

| | |
|---|---|
| - អភិបាល រាជធានី-ខេត្ត | ជាប្រធាន |
| - អភិបាលរង រាជធានី-ខេត្ត | ជាអនុប្រធាន |
| - ប្រធានមន្ទីរជុំវិញ រាជធានី-ខេត្ត | ជាសមាជិក |
| - ស្នងការនគរបាល រាជធានី-ខេត្ត | ជាសមាជិក |
| - បញ្ជាការកង រាជអាវុធហត្ថ រាជធានី-ខេត្ត | ជាសមាជិក |
| - មេបញ្ជា ការប្រតិបត្តិការ សឹករង រាជធានី-ខេត្ត | ជាសមាជិក |
| - និង នាយសាខាកាកបាទក្រហម រាជធានី-ខេត្ត | ជាសមាជិក |

**ខ- មុខងារ និងភារកិច្ច :**

- អនុវត្តគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។

- រៀបចំធ្វើការណែនាំ និងគាំទ្រដល់សកម្មភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុង-ស្រុក-ខ័ណ្ឌ ឃុំ-សង្កាត់។

- ផ្តល់យោបល់ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ចំពោះសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ កាកបាទក្រហមកម្ពុជា ការឧបត្ថម្ភរបស់អង្គការជាតិ និងអន្តរជាតិ ដែលចូលរួមទប់ស្កាត់ ត្រៀមរៀបចំសង្គ្រោះបន្ទាន់ និងស្តារឡើង វិញ ។

- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ស្តីពីការខូចខាត និងធ្វើសំណើសុំឧបត្ថម្ភថវិកា សំភារៈបរិក្ខារ មធ្យោបាយ និងកំលាំងអន្តរាគមន៍ សំរាប់ដោះស្រាយ ក្នុងពេលមាន គ្រោះមហន្តរាយ ។

- អនុវត្តកម្មវិធីបណ្តុះបណ្តាល ដើម្បីពង្រឹងជំនាញបច្ចេកទេសដល់មន្ត្រីរាជការ ក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តកម្មវិធីអប់រំជាសាធារណៈនៅក្នុងសហគមន៍ ។

គ- <u>លេខាធិការដ្ឋាន</u> :

ជាសេនាធិការ សំរាប់ធានានិរន្តរភាពការងារ ដែលដឹកនាំដោយនាយខុទ្ទកាល័យសាលា រាជធានី-ខេត្ត ធ្វើជាលេខាអចិន្ត្រៃយ៍ និងមានជំនួយការមួយចំនួន ជួយការងារតាមការចាំបាច់។

ឃ- ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត និមួយៗ មានក្រុមប្រតិបត្តិការ ចំនួន ០៤ ។

ក្រុមនិមួយៗ មានអភិបាលរង រាជធានី-ខេត្ត ០១រូបជាប្រធាន រួមមាន :

**១. ក្រុមរុករកសង្គ្រោះ និងសន្តិសុខ ដែលមានសមាសភាព :**

| | | |
|---|---|---|
| - អភិបាលរងរាជធានី-ខេត្ត | ០១រូប | ជាប្រធាន |
| - មេបញ្ជាការ កងរាជអាវុធហត្ថរាជធានី-ខេត្ត | | ជាអនុប្រធាន |

- ស្នងការនគរបាលរាជធានី-ខេត្ត ជាអនុប្រធាន
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរអប់រំយុវជន និងកីឡា រាជធានី-ខេត្ត ជាអនុប្រធាន
- តំណាងមន្ទីរពាក់ព័ន្ធ រាជធានី-ខេត្ត ជាសមាជិក

**២. ក្រុមសុខភាព និងអនាម័យ ដែលមានសមាសភាព :**

- អភិបាលរង រាជធានី-ខេត្ត ០១រូប ជាប្រធាន
- ប្រធានមន្ទីរសុខាភិបាល រាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ រាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល រាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរកិច្ចការនារី រាជធានី-ខេត្ត ជាអនុប្រធាន
- តំណាងមន្ទីរពាក់ព័ន្ធរាជធានី-ខេត្ត ជាសមាជិក

**៣. ក្រុមគ្រប់គ្រងពត៌មាន អប់រំ និង ផ្សព្វផ្សាយ ដែលមានសមាសភាព :**

- អភិបាលរង រាជធានី-ខេត្ត ០១រូប ជាប្រធាន
- ប្រធានមន្ទីរធនធានទឹក និងឧតុនិយម រាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរព័ត៌មានរាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរបរិស្ថាន រាជធានី-ខេត្ត ជាអនុប្រធាន
- តំណាងមន្ទីរពាក់ព័ន្ធ រាជធានី-ខេត្ត ជាសមាជិក

**៤. ក្រុមឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ដែលមានសមាសភាព :**

- អភិបាលរង រាជធានី-ខេត្ត-ក្រុង ជាប្រធាន
- នាយកសាខាកាកបាទក្រហម រាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ជាអនុប្រធាន
- ប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូន រាជធានី-ខេត្ត ជាអនុប្រធាន
- តំណាងមន្ទីរពាក់ព័ន្ធ រាជធានី-ខេត្ត ជាសមាជិក

## រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត




## IV- គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុង-ស្រុក-ខ័ណ្ឌ

### ក- សមាសភាព :

- អភិបាល ក្រុង- ស្រុក-ខ័ណ្ឌ ជាប្រធាន
- អភិបាលរង ក្រុង-ស្រុក-ខ័ណ្ឌ ជាអនុប្រធាន
- ប្រធានការិយាល័យ អង្គភាព ជុំវិញ ក្រុង-ស្រុក-ខ័ណ្ឌ និងប្រធានអនុសាខាកាកបាទក្រហម ក្រុង-ស្រុក-ខ័ណ្ឌ ជាសមាជិក

### ខ- មុខងារ និងភារកិច្ច :

- អនុវត្តគោលនយោបាយជាតិ ដែលពាក់ព័ន្ធក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ
- ផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយរាជធានី-ខេត្ត អំពីស្ថានភាពថ្មីៗ
- ជ្រើសរើសមន្ត្រីដើម្បីចូលរួម ក្នុងវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ រាជធានី-ខេត្ត ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ
- រៀបចំ និងផ្សព្វផ្សាយពតិមាន ដល់សាធារណជន អំពីគ្រោះមហន្តរាយ ។
- បញ្ជូនរបាយការណ៍ ស្តីពីសេចក្តីត្រូវការទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត ស្តីពីការខូចខាត និងតំរូវការផ្សេងៗ ។
- ដឹកនាំប្រតិបត្តិការ ក្នុងពេលមានគ្រោះមហន្តរាយ រួមមានជំនួយសង្គ្រោះ ការជំលៀស ការផ្តល់ ទីជំរកនិងការផ្តល់ជំនួយសុខាភិបាល ។

- បញ្ជូនរបាយការណ៍សរុប ស្តីពីប្រតិបត្តិការ ជំនួយសង្គ្រោះទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ រាជធានី-ខេត្ត ។

**គ- លេខាធិការដ្ឋាន**

ជាសេនាធិការ សំរាប់ធានានិរន្តរភាពការងារ ដែលដឹកនាំដោយប្រធានមន្ទីរ សាលាក្រុង-ស្រុក-ខ័ណ្ឌ ធ្វើជាលេខាអចិន្ត្រៃយ៍ និងមានជំនួយការមួយចំនួន ជួយការងារតាមការចាំបាច់ ។

ឃ- ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុង-ស្រុក-ខ័ណ្ឌ

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុង-ស្រុក-ខណ្ឌ និមួយៗ មានក្រុមប្រតិបត្តិការ ចំនួន ០៤ ។

ក្រុមនិមួយៗ មានអភិបាលរង រាជធានី-ខេត្ត ០១រូបជាប្រធាន រួមមាន :

**១. ក្រុមរុករកសង្គ្រោះ និង សន្តិសុខ ដែលមានសមាសភាព :**

| | |
|---|---|
| - អភិបាលរង ក្រុង-ស្រុក-ខ័ណ្ឌ ០១រូប | ជាប្រធាន |
| - មេបញ្ជាការ កងរាជអាវុធហត្ថ ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - អធិការនគរបាល ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - មេបញ្ជាការសឹករង ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - ប្រធានការិយាល័យអប់រំយុវជន និងកីឡា ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - តំណាងការិយាល័យពាក់ព័ន្ធ | ជាសមាជិក |

**២. ក្រុមសុខភាព និងអនាម័យ ដែលមានសមាសភាព :**

| | |
|---|---|
| - អភិបាលរង ក្រុង-ស្រុក-ខ័ណ្ឌ ០១រូប | ជាប្រធាន |
| - ប្រធានការិយាល័យសុខាភិបាល ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - ប្រធានការិយាល័យអភិវឌ្ឍជនបទ ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - ប្រធានការិយាល័យឧស្សាហកម្មរ៉ែ និងថាមពល ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - ប្រធានការិយាល័យកិច្ចការនារី ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - តំណាងការិយាល័យពាក់ព័ន្ធ ក្រុង-ស្រុក-ខ័ណ្ឌ | ជាសមាជិក |

**៣. ក្រុមគ្រប់គ្រងពតិមាន អប់រំនិង ផ្សព្វផ្សាយ ដែលមានសមាសភាព :**

| | |
|---|---|
| - អភិបាលរង ក្រុង-ស្រុក-ខ័ណ្ឌ ០១រូប | ជាប្រធាន |
| - ប្រធានការិយាល័យធនធានទឹក និងឧតុនិយម ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - ប្រធានការិយាល័យព័តិមាន ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - ប្រធានការិយាល័យបរិស្ថាន ក្រុង-ស្រុក-ខ័ណ្ឌ | ជាអនុប្រធាន |
| - តំណាងការិយាល័យពាក់ព័ន្ធ ក្រុង-ស្រុក-ខ័ណ្ឌ | ជាសមាជិក |

**៤. ក្រុមឆ្លើយតប សង្គ្រោះបន្ទាន់ និងសារឡើងវិញ ដែលមានសមាសភាព :**

- អភិបាលរង ក្រុង-ស្រុក-ខ័ណ្ឌ ០១រូប ជាប្រធាន
- នាយកអនុសាខាកាកបាទក្រហម ក្រុង-ស្រុក-ខ័ណ្ឌ ជាអនុប្រធាន
- ប្រធានការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រុង-ស្រុក-ខ័ណ្ឌ ជាអនុប្រធាន
- ប្រធានការិយាល័យកសិកម្មរុក្ខាប្រមាញ់ និងនេសាទក្រុង-ស្រុក-ខ័ណ្ឌ ជាអនុប្រធាន
-ប្រធានការិយាល័យសាធារណៈការ និងដឹកជញ្ជូន ក្រុង-ស្រុក-ខ័ណ្ឌ ជាអនុប្រធាន
-តំណាងការិយាល័យពាក់ព័ន្ធ ស្រុក-ខ័ណ្ឌ ជាសមាជិក

**រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ក្រុង- ស្រុក-ខ័ណ្ឌ**




## V- <u>គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់</u>

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ បានបង្កើតយោងតាមអនុក្រឹត្យលេខ ៦១ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០០៦ របស់រាជរដ្ឋាភិបាល និងលិខិតលេខ ១៨១ គ.ជ.គ.ម ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៦ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ មេឃុំ-ចៅសង្កាត់ ជាអ្នកចុះហត្ថលេខាលើដីកាបង្កើត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់ និង ក្រុមទាំង ៣។

**ក- <u>សមាសភាព</u> :**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ មានសមាសភាពដូចខាងក្រោម :

១. មេឃុំ ឬ ចៅសង្កាត់ ប្រធាន
២. ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ អនុប្រធាន
៣. ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ សមាជិក

៤. ប្រធានកម្រងសាលាបឋមសិក្សា សមាជិក
៥. ប្រធានមណ្ឌលសុខភាពឃុំ-សង្កាត់ សមាជិក
៦. ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សមាជិក
៧. ភ្នាក់ងារសុខភាពសត្វឃុំ-សង្កាត់ សមាជិក
៨. អ្នកស្ម័គ្រចិត្តកាកបាទក្រហម សមាជិក
៩. ព្រឹទ្ធាចារ្យក្នុងឃុំ សមាជិក
១០. ប្រធានភូមិគ្រប់ភូមិ សមាជិក
១១. ស្មៀន លេខាអចិន្ត្រៃយ៍

**បញ្ជាក់:** សមាសភាពខាងលើ គឺជាការចង្អុលបង្ហាញនៅពេលចេញដីកា ត្រូវកំណត់ឈ្មោះបុគ្គលទទួលខុសត្រូវឱ្យបានច្បាស់លាស់។

**ខ- រចនាសម្ព័ន្ធ :**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់មានរចនាសម្ព័ន្ធដូចតទៅ :

១. លេខាធិការដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្មៀនឃុំ និងមានបុគ្គលិកជំនួយការមួយចំនួនតាមការចាំបាច់។

២. ក្រុមសន្តិសុខ រុករកសង្គ្រោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ជាប្រធាន និង ប្រធានកម្រងសាលាបឋមសិក្សាជាអនុប្រធាន ដោយមាននគរបាលឃុំ-សង្កាត់ គ្រូ និងសិស្សស្ម័គ្រចិត្តចូលរួមជាកំលាំងប្រតិបត្តិការ។

៣. ក្រុមសុខភាព អនាម័យ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រធានមណ្ឌលសុខភាពឃុំ (ក្នុងលក្ខណៈដែល ឃុំដែលពុំទាន់មានមណ្ឌលសុខភាពត្រូវយកអនុប្រធានមណ្ឌលសុខភាពពីឃុំរួមគ្នាមកទទួលគ្រប់គ្រង) ភ្នាក់ងារសុខភាពសត្វជាអនុប្រធាន និង ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារ ជា អនុប្រធាន ដោយមានគ្រូពេទ្យឃុំ ភ្នាក់ងារសុខភាពសត្វភូមិ និងអ្នកស្ម័គ្រចិត្តជាកំលាំង ប្រតិបត្តិការ។

៤. ក្រុមឆ្លើយតបនិងព័ត៌មាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយអ្នកស្ម័គ្រចិត្តកាកបាទក្រហម ជាប្រធាន ព្រឹទ្ធាចារ្យក្នុងឃុំ ជាអនុប្រធាន និងអ្នកស្ម័គ្រចិត្ត ជាកំលាំងប្រតិបត្តិការ។

## រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅឃុំ-សង្កាត់




**គ- មុខងារ និងភារកិច្ច :**

- អនុវត្តគោលនយោបាយដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ
- កសាងផែនការត្រៀមបង្ការកាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំដើម្បីការពារអាយុជីវិត មនុស្ស-សត្វ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ផលិតផល កសិកម្ម សេវាសាធារណៈ បរិស្ថាន និង អនុវត្តដើម្បីកាត់បន្ថយគ្រោះ ភ័យ នៅពេលមានមុខសញ្ញាគ្រោះថ្នាក់ពីធម្មជាតិ និងពីមនុស្សកើតឡើង។
- សម្របសម្រួលផែនការខាងលើជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ
- រៀបចំបង្កើត និងគ្រប់គ្រងទីសុវត្ថិភាព
- រៀបចំគោលការណ៍ណែនាំ អនុវត្ត និងគាំទ្រសកម្មភាពគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍
- ជាសេនាធិការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយនិងផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និង

អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និង ភាពងាយរងគ្រោះនៅ មុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ ។

- រៀបចំចងក្រងក្រុមប្រតិបត្តិការសំរាប់ធ្វើសកម្មភាព រួមមាន :
  - ១. ក្រុមសន្តិសុខ និង រុករកសង្គ្រោះ
  - ២. ក្រុមសុខភាព និងអនាម័យ
  - ៣.ក្រុមឆ្លើយតប និង ពតិមាន
- ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមបំពេញការងារក្នុងក្រុមទាំង០៣
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់ក្រុមប្រតិបត្តិការទាំង០៣លើ ជំនាញទទួលខុសត្រូវ ព្រមទាំងអប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់មូលដ្ឋានសហគមន៍ពីគ្រោះភ័យនៃគ្រោះមហន្តរាយ មុខសញ្ញាគ្រោះថ្នាក់ វិធានការគ្រប់គ្រងគ្រោះភ័យ ។
- លើកគំរោងប្រើប្រាស់ថវិកា សំភារៈ បរិក្ខារ មធ្យោបាយប្រើប្រាស់ និងកំលាំង សំរាប់ធ្វើសកម្មភាពតាមដំណាក់នីមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយដើម្បីដាក់ស្នើតាមលំដាប់ថ្នាក់របស់ខ្លួន និងអង្គការនានា ។
- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ អំពីស្ថានភាពដែលនឹងអាចកើតមាន និង កើតមានមុខសញ្ញាគ្រោះថ្នាក់នៅមូលដ្ឋានសហគមន៍របស់ខ្លួន ។
- ធ្វើរបាយការណ៍អំពីសភាពការណ៍គ្រោះមហន្តរាយជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ ។
- ផ្តល់ពតិមានដល់ថ្នាក់លើរបស់ខ្លួនអំពីការកើតឡើងនូវមុខសញ្ញាគ្រោះថ្នាក់ឱ្យបានលឿន និង បន្ទាន់បំផុត ។
- ធ្វើការប្រជុំ១ខែម្តងជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាពរបស់ក្រុមទាំង០៣ និង ដោះស្រាយបញ្ហាដែលកើតមានរបស់ក្រុមទាំង០៣ តាមការកោះអញ្ជើញរបស់ប្រធាន និងក្នុងលក្ខណៈមានគ្រោះអាសន្ន ត្រូវមានការកោះអញ្ជើញប្រជុំបន្ទាន់ ។

**ឃ- <u>តួនាទី ការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន លេខាធិការដ្ឋាន និងក្រុមប្រតិបត្តិការ</u>**

១.<u>ប្រធាន</u> :

<u>អាណត្តិប្រធាន</u> : មេឃុំ ចៅសង្កាត់ ជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ មិនអាចយកអ្នកផ្សេងធ្វើជាប្រធានបានឡើយ ហើយមិនអាចបញ្ឈប់ពីមុខតំណែងប្រធានមុនអាណត្តិរបស់ខ្លួនជាមេឃុំ ឬចៅសង្កាត់នោះដែរ ។

<u>តួនាទីរបស់ប្រធាន</u> :

- ដឹកនាំ និងសម្រេចកិច្ចការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ក្នុងនាមជាប្រធាន និងក្នុងក្របខ័ណ្ឌជាមេឃុំ និងចៅសង្កាត់ រួមទាំងការចុះហត្ថលេខាលើការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ- សង្កាត់ ក្រុមប្រតិបត្តិការទាំង០៣ ការណែនាំ ការប្រកាសប្រាប់ឱ្យដឹងមុនពីគ្រោះអាសន្ននៅក្នុងឃុំ-សង្កាត់របស់ខ្លួន និងចេញលិខិតកោះអញ្ជើញប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ។

- ដឹកនាំការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ។

- ធ្វើសហប្រតិបត្តិការ និង ដឹកនាំការអនុវត្តន៍គំរោងកម្មវិធីការងារគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូនានា ដែលត្រូវអនុវត្តនៅក្នុងឃុំ-សង្កាត់របស់ខ្លួន។

- ដឹកនាំការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់របស់ខ្លួន។

- ដឹកនាំការងារបណ្តុះបណ្តាលសំរាប់សកម្មភាពត្រៀមបង្ការ និងត្រៀមរៀបចំ ឆ្លើយតបគ្រោះអាសន្ន និងការស្តារ ការស្តាបនាឡើងវិញ ដោយបញ្ជ្រាបការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការអភិវឌ្ឍសហគមន៍មូលដ្ឋាន។

២. <u>អនុប្រធាន</u> :

<u>អាណត្តិអនុប្រធាន</u> : ជំទប់ទី១ ចៅសង្កាត់រងទី១ ជាអនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ មិនអាចយកអ្នកផ្សេងធ្វើជាអនុប្រធាន ហើយមិនអាចបញ្ឈប់ពីមុខតំណែងអនុប្រធានមុនអាណត្តិរបស់ខ្លួនជាជំទប់ទី១ និងចៅសង្កាត់រងទី១នោះដែរ។

<u>តួនាទីរបស់អនុប្រធាន</u> : ជួយការងារប្រធាន និង ជំនួសប្រធាននៅពេលប្រធានអវត្តមាន។

៣. លេខាធិការដ្ឋាន :

ត្រូវបានបង្កើតឡើងដើម្បីជាសេនាធិការឱ្យប្រធាន និងអនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ក្នុងការបូកសរុបសភាពការណ៍បង្កបង្កើនផល គ្រោះមហន្តរាយ និងសកម្មភាពរបស់ក្រុមទាំង៣ ដើម្បីរាយការណ៍ ជូនថ្នាក់បន្តបន្ទាប់ដែលទទួលការងារគ្រប់គ្រងគ្រោះមហន្តរាយ ហើយមានតួនាទីទទួលខុសត្រូវលើការងារ :

- ទទួល និង ផ្តល់ពតិមានបន្ទាន់ពីមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះអាសន្នផ្សេងៗដោយមនុស្ស និងធម្មជាតិ
- ទទួលរបាយការណ៍ និង គ្រប់គ្រងទុកដាក់ឯកសារ
- បូកសរុបសភាពការណ៍ និង តាមដានត្រួតពិនិត្យវាយតំលៃ
- ធ្វើកំណត់ហេតុប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ។

៤. ក្រុមសន្តិសុខ និងរុករកសង្គ្រោះ

ត្រូវបានបង្កើតឡើងដើម្បីរៀបចំ ត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្ស និងធម្មជាតិ ធ្វើប្រតិបត្តិការនៅពេលមានគ្រោះអាសន្ន រំដោះប្រជាជនចេញពីគ្រោះថ្នាក់ ជម្លៀសប្រជាជន ការពារសន្តិសុខ សុវត្ថិភាព ពន្លត់អគ្គីភ័យ រុករក និងសង្គ្រោះអ្នករងគ្រោះ ព្រមទាំងមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

- កសាងផែនការ រៀបចំកំលាំង មធ្យោបាយ សំភារៈសំរាប់បំរើការរុករក និងសង្គ្រោះ និងសន្តិសុខសណ្តាប់ធ្នាប់។

- អប់រំ ផ្សព្វផ្សាយ និងពន្យល់ដល់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ អំពីវិធានការត្រៀមបង្ការ កាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំសំរាប់កាត់បន្ថយគ្រោះអាសន្ន និងគ្រោះភ័យផ្សេងៗ ព្រមទាំងខ្លឹមសារ និងសញ្ញាប្រកាសអាសន្ន និងសកម្មភាពត្រូវអនុវត្ត។

- កំណត់ការផ្តល់សញ្ញាពីលំនៅដ្ឋានមួយទៅលំនៅដ្ឋានមួយដើម្បីងាយស្រួលពេលមានគ្រោះអាសន្នកើតឡើង។

- ថែរក្សាទុកដាក់ឱ្យបានល្អនូវឧបករណ៍ មធ្យោបាយប្រកាសអាសន្ន (មេក្រូ ជួង ត្រដោក ស្គ ចង្កៀង) ធានាថា ប្រើប្រាស់បាន។

- រៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ ទីសុវត្ថិភាព និងគំនូសបង្ហាញផ្លូវពីកន្លែងមានប្រជាពលរដ្ឋរស់នៅ ទៅកាន់កន្លែងជម្លៀស ហើយនឹងមានបញ្ជីប្រជាជនដែលអាចត្រូវជម្លៀស។

- កន្លែងដែលកំណត់ទុកសំរាប់ជម្លៀស គឺផានាអាចប្រើប្រាស់បាន មានសុវត្ថិភាព និង ធ្វើផែនការជម្លៀស បង្កើតវិធីសាស្ត្រក្នុងការជម្លៀសឱ្យមានប្រសិទ្ធភាពតាមផែនការ ។

- ការពារសន្តិសុខ កន្លែងស្នាក់នៅបណ្តោះអាសន្នរបស់ជនរងគ្រោះ និងការពារមិនឱ្យមានការបន្លំចូលលួច ប្លន់ ព្រមទាំងថែរក្សា ការពារទ្រព្យសម្បត្តិ ផ្ទះសម្បែងប្រជាពលរដ្ឋបានចោលបណ្តោះអាសន្នទៅទីសុវត្ថិភាព ។

-ត្រួតពិនិត្យការចេញចូលនៅតំបន់កើតហេតុ និងទីសុវត្ថិភាព ។

- ដាក់ផ្លាកសញ្ញាតំបន់គ្រោះថ្នាក់ និងសញ្ញាសំគាល់ និងសញ្ញាហាមឃាត់ផ្សេងៗ ។

- ផ្តល់កំលាំងការពារក្បួនដឹកជញ្ជូនសំភារៈ បរិក្ខារ និងប្រតិភូដែលចូលមកបំពេញការងារនៅតំបន់រងគ្រោះ ។

- រៀបចំកំលាំងប្រតិបត្តិការដំណាក់កាលដំបូងសំរាប់ពន្លត់អគ្គីភ័យ ។

- ផ្សព្វផ្សាយវិធានការផ្សេងៗ ដែលជាលក្ខណៈត្រៀមបង្ការនូវយថាហេតុនៃមុខសញ្ញាគ្រោះថ្នាក់ដោយមនុស្ស តាមមធ្យោបាយដែលអាចធ្វើបាន ។

- ដឹកនាំបុគ្គលិកសង្គ្រោះ និងសំរបសំរួល ធ្វើការបណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋម និងជួយសង្គ្រោះ ។

៥. ក្រុមសុខភាព និងអនាម័យ

ត្រូវបានបង្កើតឡើង ដើម្បីធ្វើប្រតិបត្តិការការពារអាយុជីវិតប្រជាជន តាមរយៈការគាំពារសុខភាព ស្រាវជ្រាវរកប្រភពនៃជំងឺ និងការពារជំងឺឆ្លងទាំងមនុស្ស សត្វ ជំងឺរាតត្បាត ជម្លៀសអ្នកជំងឺទៅតាមកន្លែងមន្ទីរពេទ្យ សង្គ្រោះបន្ទាន់ ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

- អប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីការថែរក្សាសុខភាព ការទទួលទានចំណីអាហារ ការត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ ដែលបង្កដោយមនុស្ស និងធម្មជាតិ

- បណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋម ថែទាំសុខភាព អនាម័យដល់សហគមន៍

- អប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់ អំពីរោគសញ្ញាផ្សេងៗនៃជំងឺសត្វ ការការពារ ការព្យាបាលជំងឺសត្វ ការសំអាតអនាម័យទ្រុងសត្វ និងអនាម័យខ្លួនប្រាណមនុស្ស ការបរិភោគ ចំអិនសាច់សត្វ

- រិះរកវិធីសាស្ត្រ សំរាប់ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះជួយខ្លួនឯង និងប្រើប្រាស់អ្វីដែលមានក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបពេលមានជួបគ្រោះអាសន្នកើតឡើង

-ត្រួតពិនិត្យ និង ក្តាប់ជាប់ជាប្រចាំនូវស្ថិតិសត្វចិញ្ចឹមនៅក្នុងឃុំ-សង្កាត់

- ចាក់ថ្នាំបង្ការជំងឺសត្វ

-ត្រួតពិនិត្យមិនឱ្យមានការទិញលក់សត្វឈឺ និងសត្វស្លាប់ដោយជំងឺនិងការដឹកជញ្ជូនសត្វនៅក្នុងរង្វង់ឃុំ-សង្កាត់

- ពង្រឹងបទបញ្ជាអនាម័យ អនុវត្តផែនការត្រួតពិនិត្យតំបន់កខ្វក់ ការចាក់សំរាម

-ត្រួតពិនិត្យស្ថានភាពអនាម័យរបស់សហគមន៍ អណ្តូងទឹក ស្រះទឹក និងការប្រើប្រាស់ទឹក

- កំណត់ទីកន្លែង អាគារដែលអាចប្រើប្រាស់ជាមូលដ្ឋាន ធ្វើស្នាក់ការពេទ្យពេលមានគ្រោះអាសន្នកើតឡើង និងគ្រប់គ្រងព្យាបាលដល់អ្នកជំងឺស្រាល ។

៦. ក្រុមឆ្លើយតប និងព័ត៌មាន :

ត្រូវបានបង្កើតឡើង ដើម្បីធ្វើប្រតិបត្តិការផ្តល់ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្ស ដែលកើតឡើងនៅមូលដ្ឋានឃុំ-សង្កាត់ ទាក់ទងនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលរងគ្រោះ និងធ្វើការចែកផ្សាយ

ព័ត៌មាន បង្ហាញហេតុផល ព្រមទាំងធ្វើការអំពាវនាវរកជំនួយ ផ្តល់ជំនួយដល់ក្រុមរងគ្រោះ អនុវត្តគំរោងពលកម្ម ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម ៖

- សហការជាមួយអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល កសាងគំរោងត្រៀមបង្ការគ្រោះមហន្តរាយតាមបែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធ

- រៀបចំទីសុវត្ថិភាពឱ្យមានលក្ខណៈសមស្របអាចស្នាក់នៅបាន

- ស្រង់ចំនួនប្រជាជនរងគ្រោះ ដែលជម្លៀសទៅរស់នៅតាមទីសុវត្ថិភាព

- ផ្តល់ការស្នាក់នៅដល់ប្រជាជនរងគ្រោះ រៀបចំជំរកបណ្តោះអាសន្ន ឬនៅតាមគេហដ្ឋានដែលម្ចាស់គេអនុញ្ញាត

- គ្រប់គ្រងសំភារៈជំនួយសង្គ្រោះដូចជាអង្ករ ស្បៀងអាហារ...

- រាយការណ៍ពីស្ថានភាពជនរងគ្រោះ និងសកម្មភាពផ្តល់ជំនួយ វាយតំលៃការខូចខាត និងសេចក្តីត្រូវការ ។

- តាមដានត្រួតពិនិត្យសុខុមាលភាពរបស់ប្រជាជនរស់នៅក្នុងទីសុវត្ថិភាព ។

- ចែកចាយអំណោយសំភារៈសង្គ្រោះបន្ទាន់ ។

- ដាស់សតិអារម្មណ៍ និងបំផុសស្មារតីលើកទឹកចិត្ត ។

- ស្វែងរកបញ្ហាផ្សេងៗ និង ព្យាយាមដោះស្រាយបញ្ហា ។

- រៀបចំផ្តល់ឱកាសរកការងារដល់ជនរងគ្រោះ ដូចជា ៖ កម្មវិធីស្បៀងពលកម្ម និងប្រាក់ពលកម្ម ផ្តល់មីក្រូឥណទានជាដើម ។